# ការចងចាំ

## ដោយ យឹម ម៉ាលីន

ម៉ាលីន ខិតខំធ្វើការងារសិល្បៈយ៉ាងហ្មត់ចត់បំផុត ដោយប្រើប្រាស់នូវសម្ភារៈផ្សេងៗចំរុះគ្នា ហើយពិនិត្រពិច័យយ៉ាងល្អិតល្អន់លើទស្សនៈដ៏ស្មុគស្មាញស្តីពី *សេរីភាព* ។ ដោយធំដឹងក្តីក្រោយរបបខ្មែរក្រហម រយៈពេលក្នុងវ័យកុមាររបស់ម៉ាលីន បើតាមបរិបទនយោបាយគេចាត់ទុកថាវាជាពេលវេលាដែលប្រកបដោយសេរីភាព ។ ប៉ុន្តែ ម៉ាលីនកត់សំគាល់ឃើញមានភាពផ្ទុយគ្នាទៅវិញ ។ ពិព័រណ៍ *ការចងចាំ* នឹងបង្ហាញជូននូវស្នាដៃពណ៌សខ្មៅចំនួនបួន ស្តីពីការចងចាំរបស់ម៉ាលីនកាលពីកុមារភាព ដែលក្នុងនោះភាពសប្បាយរីករាយនិងក្តីព្រួយបារម្ភនៅលាយឡំគ្នា។

ម៉ាលីន បានប្រែក្លាយផ្ទះបាយដ៏ចាស់របស់គ្រួសារនាង ទៅជាកន្លែងលេងកំសាន្តមួយដ៏ចម្លែក។ *បាយឡុកបាយឡ* (២០១០) គឺជាស្នាដៃបែប Installation នៅលើកំរាលឥដ្ឋដែលរាយប៉ាយទៅដោយដី និងមានវត្ថុចំនួនបីប្រភេទធ្វើពីដីដុតសូនដោយដៃគឺ កាំបិត ចាន និងឆ្អឹង។ *មុខថ្មី* (២០១០) ជារបាំងមុខចំនួនប្រាំបួនធ្វើពីម្នាងសីលា ដែលដាក់ភ្ជាប់ទៅនឹងជញ្ជាំង។ ម៉ាលីនបានបង្កើតរបាំងមុខទាំងនេះចេញពីផ្នែកផ្សេងៗគ្នានៃមុខ បន្ទាប់មកផ្គុំគ្នាទៅជារបាំងមុខដើម្បីឆ្លុះបញ្ចាំងពីជីវិតបែកខ្ញែកក្នុងអំឡុងពេលសង្គ្រាម និងក្រោយសង្គ្រាម ។

ស្នាដៃនៅចំកណ្តាលនៃពិព័រណ៍នេះគឺ រូបចម្លាក់ខ្លែងមួយមានប្រវែងបួនម៉ែត្រដែលមានឈ្មោះថា *ក្តីសង្ឃឹម* (២០១០)។ ការធ្វើខ្លែង និងបង្ហោះខ្លែងបានរស់រានឡើងវិញប៉ុន្មានទសវត្សក្រោយពេលការលុបបំបាត់វប្បធម៌ក្នុងរបបខ្មែរក្រហម ។ ម៉ាលីនចងចាំពីការបង្ហោះខ្លែង ពិសេសនៅចុងរដូវវស្សានិងដើមរដូវប្រាំង ដែលជាពេលវេលាពោរពេញទៅដោយក្តីសង្ឃឹមក្នុងការប្រមូលផលស្រូវ ។ ដោយឡែក ខ្លែងរបស់សិល្បការិនីរូបនេះ ធ្វើពីសេរ៉ាមិចខុសពីខ្លែងធម្មតាដែលធ្វើពីសូត្រ ឬក្រដាស ហើយស្រាលនិងជាប់បានយូរ ។ ស្នាដៃខ្លែងឯកឈ្មោះ *ក្តីសង្ឃឹម* នេះគឺផ្ទុយពីសេចក្តីរំពឹងទុករបស់យើង ចំពោះវត្ថុប្រកបដោយភាពសប្បាយ និងកំសាន្តនេះ។ ដោយមានទម្ងន់ធ្ងន់ មានពណ៌ខ្មៅ និងមានសភាពស្ងប់ស្ងាត់ ខ្លែងឯកនេះមានកន្ទុយធ្វើពីសេរ៉ាមិចដ៏ផុយស្រួយដាក់សន្ធូកលើកម្រាលឥដ្ឋ ហើយការហោះហើររបស់វាគ្រាន់តែជាការបំភាន់ភ្នែកតែប៉ុណ្ណោះ។

*ស្នាមរបួស ១-៤* (២០១០) ជាស៊េរីគំនូរខ្មៅដៃដែលគូរយ៉ាងផ្ចិតផ្ចង់ចំនួនបួនផ្ទាំងដែលសិល្បការិនីបានស្រមៃពីទំរង់ផ្ទុះនៃសំណុំគ្រាប់អង្ករ ។ ម៉ាលីនលើកឡើងថា “នៅកម្ពុជាក៏ដូចជានៅបណ្តាប្រទេសផ្សេងៗនៅអាស៊ីដែរ គឺមនុស្សធ្វើការដើម្បីបានបាយទទួលទាន ហេតុដូច្នេះរាងកាយរបស់មនុស្សយើងគឺកើតចេញពីគ្រាប់អង្ករ ។” ការផ្ទុះគ្រាប់អង្ករនេះ តំណាងឲ្យការរួចផុតពីសម្ពាធដ៏តានតឹង ។ អត្ថន័យនៃការផ្ទុះនេះគឺចង់បង្ហាញថា វាជាពេលវេលាមួយដែលត្រូវបើកចំហរ ធ្វើដំណើរ និងសិក្សាស្វែងយល់ ។ ទោះជាយ៉ាងណា ចំណងជើង *ស្នាមរបួស* នេះគឺជាការក្រើនរំលឹកពីអ្វីមួយដែលតែងតែនៅជាប់ជាមួយយើងជានិច្ច ។

យឹម ម៉ាលីន កើតនៅខេត្តបាត់ដំបងក្នុងឆ្នាំ១៩៨២ ហើយបច្ចុបន្នរស់នៅក្នុងខេត្តសៀមរាប ។ គាត់បានសិក្សាជំនាញសិល្បៈនៅសាលាហ្វាពន្លឺសិល្បៈក្នុងប្រទេសកម្ពុជា (១៩៩៥-២០០៣) បន្ទាប់មកទទួលបាន បរិញ្ញាបត្រសិល្បៈផ្នែកសូនរូប ពីសាលាវិចិត្រសិល្បៈនៃទីក្រុងកង់ (Caen la mer) នៅឆ្នាំ ២០១០ ។ ម៉ាលីន បានចូលរួមនៅក្នុងពិព័រណ៍សិល្បៈជាច្រើននៅក្នុងប្រទេសបារាំង និងកម្ពុជា ។ *ការចងចាំ* គឺជាពិព័រណ៍ តែម្នាក់ឯងលើកទីមួយរបស់ម៉ាលីន ។

# Remember

## Yim Maline

Yim Maline's rigorous practice spans media and scrutinizes the complexities of freedom. Growing up after the official fall of the Khmer Rouge, Yim's childhood years are considered politically "free", yet she notes contradictions. *Remember* presents four achromatic interpretations of the artist's childhood memories, in which the playful and the unsettling coincide.

Yim turns her family's poor dinette into an eerie playground. *Dinette* (2010) is a sprawling floor installation of dirt scattered with three hand-built, unglazed ceramic objects in series: knives, bowls, and bone-like shapes. *New Face* (2010) is a collection of nine rough plaster masks attached to the wall. The artist cast pieces of a face repeatedly, after which she anarchically pieced together the parts to reflect the disjointed nature of life during and after war.

The centerpiece of the exhibition is a four-meter-long sculpture of a kite entitled *Hope* (2010). Kite-making and flying survived decades of cultural censorship during the Khmer Rouge. The artist remembers flying kites, especially at the end of the monsoon season and the beginning of the dry season – a time filled with hope for a rice harvest. In the artist's adaptation, the customary kite named *Khleng Ek* is built of ceramic rather than the typical light and durable materials of silk or paper. *Hope* defies one's expectations of a vibrant and celebratory recreational object. Heavy, black and silent, *Hope*'s fragile, ceramic tails rests on the floor, its flight a mere illusion.

*Scar 1-4* (2010) is a series of meticulous graphite-on-paper drawings in which the artist has imagined explosions of organically shaped rice clusters. Yim says, "In Cambodia, like most of Asia, we work for rice; our bodies are built of rice." An explosion indicates a necessary release of pressure. The peculiar explosions in *Scar* are symbolic of a time to open, to travel, to learn. The title however is a reminder of something that never goes away.

**About the Artist**

Yim Maline was born in Battambang in 1982 and is currently based in Siem Reap. She studied art at Phare Ponleu Selapak, Cambodia (1995-2003), and received her Diplôme National Arts Plastique (DNAP, Art Option), École Supérieure des Beaux-arts, Caen la mer, France (2010). She has participated in numerous exhibitions in France and Cambodia. *Remember* is Yim Maline's first solo exhibition.


+855 (0)17774864
www.sasabassac.com

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

ស-សបាសាក់ SA SA BASSAC

# ការចងចាំ
## ដោយ  យឹម ម៉ាលីន

# Remember
## Yim Maline

7 April - 8 May 2011



*Scar 3*, 2010
graphite on paper
79 x 110 cm



*Hope*, 2010
ceramic, bamboo, rattan, string
460 x 100 x 6 cm



*Remember*